ពុទ្ធិកសមាគមវត្តខ្មែរម៉ូដេស្តូ

MODESTO CAMBODIAN BUDDHIST SOCIETY, INC.

1528/1538 Grimes Avenue, Modesto, California 95358

Phone: (209) 522-3138


# បុណ្យឆ្លងសាលាធម្មសភា

ខ្ញុំព្រះករុណា អាត្មាភាព យើងខ្ញុំទាំងអស់គ្នា ជាព្រះសង្ឃ អាចារ្យ គណៈកម្មការ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្តខ្មែរម៉ូដេស្តូទាំងមូល បានមូលមតិគ្នាជាឯកច្ឆ័ន្ទប្រារព្ធធ្វើបុណ្យឆ្លងសាលាធម្មសភាដែលបានដំណើរសាងសង់អស់រយៈកាល១០ឆ្នាំ ឥឡូវនេះបានសាងសង់រួចរាល់និងសាលាក្រុងម៉ូដេស្តូបានទទួលស្គាល់និងអនុញ្ញាតឱ្យយើងចូលទៅប្រើប្រាស់តាមតម្រូវការហើយ។

អាស្រ័យដូចបានប្រគេននិងជំរាបជូនខាងលើនេះ ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំ សូមនិមន្តព្រះតេជគុណគ្រប់ព្រះអង្គនិងគោរពអញ្ជើញ អស់លោក លោកស្រី អ្នកនាងកញ្ញា និងពុទ្ធបរិស័ទជិតឆ្ងាយ និមន្តនិងអញ្ជើញចូលរួមក្នុងពិធីបុណ្យនេះ អោយបានច្រើនកុះករនិងសូមអនុមោទនាយកនូវអានិសង្សរៀងៗខ្លួនតាមសេចក្តីប្រាថ្នា ។

## កម្មវិធីបុណ្យ/program

ថ្ងៃ៧កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ត្រូវនឹង ថ្ងៃសុក្រ ទី១ ខែសីហា ឆ្នាំ២០២៥ (Friday August 1, 2025 @ 4:30 P.M.) វេលាម៉ោង៤:៣០នាទីរសៀល ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយនមស្សការព្រះរតនត្រៃ សមាទានសីល និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ។

លុះព្រឹកឡើងថ្ងៃសៅរ៍ ទី២ ខែឆ្នាំដដែល (Saturday August 2, 2025 @ 9:00 A.M.) នមស្សការ ព្រះរតនត្រៃ, សមាទានសីល រាប់បាត្រ វេរភត្តប្រគេនដល់ព្រះសង្ឃ ព្រះសង្ឃសូត្រពហូទេវាជាកិច្ចឆ្លងបុណ្យ។

ធ្វើនៅវត្តខ្មែរម៉ូដេស្តូ, ថ្ងៃសៅរ៍ ទី២១ ខែមិថុនា ឆ្នាំ២០២៥

| ព្រះចៅអធិការ | អាចារ្យសម្រាប់វត្ត | ប្រធានគណៈកម្មការនាយក |
|---|---|---|
| ភិក្ខុយិន សួន | ស៊ុន សុផន | ខាន់ ព្រុំ |